# បន្ទប់ស្ថានការណ៍ ថ្ងៃបោះឆ្នោត ឆ្នាំ២០១៣

## Situation Room on Cambodia Election Day 2013

---

ភ្នំពេញ ថ្ងៃទី០១ មីនា ២០១៤

**សេចក្តីថ្លែងការណ៍**
**ស្តីពី**
**អនុសាសន៍សម្រាប់កិច្ចប្រជុំនៃក្រុមការងាររបស់គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ**

អង្គការសង្គមស៊ីវិលសូមអបអរសេចក្តីប្រកាសរួមនៃក្រុមការងារគណបក្សនយោបាយទាំងពីរ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ២០១៤ និងការគ្រោងជួបប្រជុំគ្នាជាថ្មីនៃក្រុមការងារទាំងពីរ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤ ខាងមុខនេះ។ យើងខ្ញុំសូមផ្តល់ជាអនុសាសន៍ ដូចខាងក្រោមសម្រាប់កិច្ចប្រជុំនេះ៖

- សមាសភាពនៃគណៈកម្មាការចម្រុះកំណែទម្រង់បោះឆ្នោតនេះ គួរមានសមាជិកជាស្ត្រីមកពីគណបក្សនយោបាយទាំងពីរ។
- ដំណើរការនៃគណៈកម្មការចម្រុះកំណែទម្រង់ការបោះឆ្នោតនេះ ត្រូវតែមានការបើកចំហរ និងការផ្តល់នូវព័ត៌មានជូនសាធារណជន។
- នីតិវិធីធ្វើការរបស់គណៈកម្មការនេះត្រូវធានាឱ្យមានការស្រុះស្រួលគ្នាជាឯកច្ឆ័ន្ទ និងភាពរលូននៃដំណើរការ ។
- គណៈកម្មការនេះត្រូវសម្រេចអោយបាននូវបញ្ជីលទ្ធផលដែលបានរំពឹងទុក នៃកំណែទម្រង់នៃការបោះឆ្នោត (មានជាអាទិ៍ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត បញ្ជីឈ្មោះបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយ យន្តការដោះស្រាយទំនាស់ការបោះឆ្នោត និងការលើកស្ទួយស្ត្រី និងយុវជនតំណាងជាប់ឆ្នោត...) និងបង្កើតផែនការសម្រាប់ការអនុ

វត្តការកំណែទម្រង់ការបោះឆ្នោតដែលព្រមព្រៀងគ្នា អោយបានច្បាស់លាស់នៅមុនដំណាច់ឆ្នាំ២០១៤។

- ការអនុវត្តន៍ផែនការកំណែទម្រង់ការបោះឆ្នោតនេះគួរធានាអោយមានការរៀបចំការបោះឆ្នោតឡើងវិញមុនអាណត្តិ យ៉ាងយូរមុនដំណាច់ឆ្នាំ២០១៥។

ក្រុមអង្គការសង្គមស៊ីវិល សង្ឃឹមយាងមុតមាំថា ការជួបប្រជុំនៃក្រុមការនៃគណបក្សនយោបាយទាំងពីរ នឹងប្រកបទៅដោយការទទួលខុសត្រូវ និងទទួលបានលទ្ធផលវិជ្ជមាន។

**<u>អង្គការដែលគាំទ្រ និងព័ត៌មានបន្ថែមសូមទាក់ទង៖</u>**

| | | |
|---|---|---|
| ១.លោកស្រី រស់ សុភាព | នាយិកាអង្គការ GADC | ០១២ ៦២ ៧៨ ៥៧ |
| ២.លោក ហង្ស ពុទ្ធា | នាយកប្រតិបត្តិអង្គការនិកហ្វិច | ០១២ ៩៥ ៩៦ ៦៦ |
| ៣.លោក សួន ប៊ុនស័ក្តិ | អគ្គលេខាធិការនៃ CHRAC | ០៩២ ៣៤ ៤៣ ៥៧ |
| ៤.លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | ០១២ ៨០ ១២ ៣៥ |
| ៥.លោក ប៉ា ងួនទៀង | នាយកប្រតិបត្តិ CCIM | ០៦០ ៤០ ៩៩ ៩៩ |
| ៦.លោក យ៉ង់ គឹមអេង | នាយកប្រតិបត្តិ PDP-Center | ០១៦ ៨២ ៨២ ១១ |
| ៧.លោក ជាង សុខា | នាយកប្រតិបត្តិអង្គការ YRDP | ០១២ ៣៦ ០៤ ៦៤ |
| ៨.លោក សាម អ៊ីន | នាយកប្រតិបត្តិ LWD | ០១២ ៥៥ ១៨ ៨៦ |
| ៩.លោក នី ចរិយា | ប្រធានស៊ើបអង្កេតនៃសមាគម អាដហុក | ០១១ ២៧ ៤៩ ៥៩ |
| ១០.លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ០១២ ៩៤ ២០ ១៧ |
| ១១.លោក ហុង គឹមសួន | ប្រធានសម្ព័ន្ធCISA | ០១២ ៩៤ ៥៥ ០៥ |
| ១២.លោក គាន ពន្លក | នាយកប្រតិបត្តិស្តីទីអង្គការDHRAC | ០១២ ៥៥ ១៤ ៦៦ |